# ក្រសួងអប់រំនៃទីក្រុងហ្វីឡាដែលហ្វ្យ៉ា

## ការិយាល័យផ្នែក ចុះឈ្មោះ និង ចាត់តាំង សិស្ស

### វិធីជ្រើសរើសសាលា សម្រាប់ឆ្នាំសិក្សា ២០១៥-២០១៦

បញ្ជីផ្ទៀងផ្ទាត់សម្រាប់សិស្សដែលមិនមែនជាសិស្សរបស់ក្រសួង



*ត្រៀមខ្លួនជាមុន*

✓ ពិនិត្យមើលរបាយការណ៍សិក្សានៃឆ្នាំដែលសិស្សទើបនឹងរៀនចប់ថ្មីៗ។ នេះរួមមាន ប៉ុន្តែគ្មានកំណត់ដូចជា ពិន្ទុ វត្តមានអវត្តមាន អាកប្បកិរិយា និង លទ្ធផលនៃការប្រឡងទូទៅ។

✓ រកមើលសាលាដែលសិស្សចង់ដាក់ពាក្យសុំចូលរៀន (ចូលរួមក្នុងពិធីពិព័រណ៍វិទ្យាល័យ ប្រើអ៊ិនធ័រណិត ណាត់ពេលទៅមើលសាលា ប្រើព័ត៌មានដែលលោកអ្នកមានទាំងអស់ ដើម្បីស្វែងយល់អំពីសាលាទាំងនោះ)។

✓ សម្រាប់សាលាដែលយោងទៅលើលក្ខណវិនិច្ឆ័យ (សាលា ឬ កម្មវិធី ទទួលសិស្សដែលមានលក្ខណសម្បត្តិពិសេស ទទួលសិស្សទូទាំងក្រុង) ធ្វើយ៉ាងណា ប្រៀបធៀប តម្រូវការនៃការទទួលសិស្សរបស់សាលា ជាមួយនឹងរបាយការណ៍សិក្សារបស់សិស្ស។

*ការដាក់ពាក្យសុំចូលរៀន*



✓ សូមមើលវ៉ិបសៃ schoolselect.philasd.org។ (កុំសរសេរ www. នៅខាងមុខអាស័យដ្ឋានវ៉ិបសៃ)

✓ ចុចលើប្រអប់ពណ៌ខៀវដែលមានពាក្យថា “I'm a Non-School District of Philadelphia, APPLY NOW!” នេះជាប្រអប់សម្រាប់សិស្សានុសិស្សដែលបច្ចុប្បន្ននេះរៀននៅ សាលាឆាធ័រ សាលាឯកជន ឬសាលាសាសនា។ ប្រអប់នេះក៏សម្រាប់ ក្រុមគ្រួសាររបស់សិស្សថ្នាក់មុនមត្តេយ្យដែលដាក់ពាក្យសុំចូលរៀននៅសាលាដែលនៅក្រៅតំបន់រស់នៅរបស់ខ្លួន សម្រាប់សិស្សថ្នាក់មត្តេយ្យដែលចាប់ផ្តើមនៅខែកញ្ញា ឆ្នាំ ២០១៦។

✓ បំពេញលិខិតដាក់ពាក្យសុំចូលរៀន។ សិស្សអាចជ្រើសរើសសាលាដល់ទៅប្រាំ ដែលជាសាលារបស់ក្រសួងអប់រំនៃទីក្រុងហ្វីឡាដែលហ្វ្យ៉ា។

✓ បញ្ជាក់ឲ្យច្បាស់ថា អ៊ីមែលរបស់លោកអ្នកត្រឹមត្រូវ។ នេះជាការសំខាន់ណាស់! ក្រសួងអប់រំនឹងអ៊ីមែលទៅលោកអ្នកគ្រប់ការទាក់ទងទាំងអស់ (ការសម្រេចចិត្តទទួលសិស្ស ការផ្តល់ដំណឹង ព័ត៌មានថ្មីៗ ។ល។) ក្រោយពេលលោកអ្នកបានដាក់ពាក្យរួចហើយ។

✓ **សូមកត់សម្គាល់**! ក្រោយពេលដាក់ពាក្យរួចហើយ **<u>មិនអាចកែប្រែវិញបានទេ</u>។** សូមពិនិត្យឲ្យច្បាស់ថា ព័ត៌មានទាំងអស់ ត្រឹមត្រូវ ពិតប្រាកដ មុននឹងចុចប្រអប់ submit។ បើសិនជាលោកអ្នកដាក់ពាក្យសុំចូលរៀនមួយទៀត សម្រាប់សិស្សដដែល ក្រសួងអប់រំនឹងប្រើ លិខិតដាក់ពាក្យសុំចូលរៀន ដែលលោកអ្នកផ្តល់ឲ្យ**<u>ក្រោយបង្អស់</u>**។ **<u>គេនឹងលប់ចោលនូវលិខិតដាក់ពាក្យសុំចូលរៀនពីមុនទាំងអស់។</u>**

*ការផ្តល់ របាយការណ៍សិក្សា និងឯកសារគាំទ្រ*



បេក្ខជនដាក់ពាក្យសុំចូលរៀនដែលមិនមែនជាសិស្សរបស់ក្រសួងអប់រំនៃទីក្រុងហ្វីឡាដែលហ្វ្យ៉ាគ្រប់រូប **<u>ត្រូវ</u>**ផ្ញើរបាយការណ៍សិក្សាពីឆ្នាំមុនទាំងអស់ ទៅឲ្យសាលា**<u>នីមួយៗ</u>** ដែលពួកគេបានដាក់ពាក្យសុំចូលរៀន។ នេះរួមមាន ប៉ុន្តែគ្មានកំណត់ ដូចជា៖

- ✓ របាយការណ៍ពិន្ទុចុងក្រោយបង្អស់
- ✓ លទ្ធផលនៃការប្រឡងទូទៅចុងក្រោយបង្អស់
- ✓ របាយការណ៍វត្តមានអវត្តមានចុងក្រោយបង្អស់
- ✓ របាយការណ៍អាកប្បកិរិយាចុងក្រោយបង្អស់
- ✓ អត្ថបទ ឬ ការសរសេរតំរូ បើសិនជាប់ពាក់ព័ន្ធ
- ✓ លិខិតគាំទ្រ បើសិនជាប់ពាក់ព័ន្ធ
- ✓ បើសិនជាកូនលោកអ្នកមាន IEP, 504 Plan ឬ ចូលរួមក្នុងកម្មវិធី ESOL សូមទាក់ទងទៅអ្នកផ្តល់ឱវាទនៅសាលារបស់កូនលោកអ្នក ដើម្បីពិភាក្សាអំពី វិធីគាំទ្រតាមកម្មវិធី ឡាហ្គែ (LeGare Advocacy Process)

**សូមកត់សម្គាល់**! បេក្ខជនដាក់ពាក្យសុំចូលរៀនទាំងអស់ ត្រូវដាក់ពាក្យសុំចូលរៀនតាមអ៊ិនធ័រណិត **<u>និង</u>** ផ្តល់របាយការណ៍សិក្សារបស់ពួកគេ ទៅសាលានីមួយៗ ដែលមានបញ្ជាក់នៅលើលិខិតដាក់ពាក្យថាទទួលសិស្សតាមលក្ខណវិនិច្ឆ័យ។ **<u>បេក្ខជនដែលមិនបានផ្តល់ឯកសារទាំងពីរប្រភេទនេះ គេនឹងមិនពិចារណាដល់ការទទួលសិស្សឲ្យចូលរៀនទេ។</u>**

*ការសួរនាំជាបន្ត*

- ✓ សូមទាក់ទងទៅសាលាដែលមាននៅលើលិខិតដាក់ពាក្យសុំចូលរៀនរបស់អ្នក ដើម្បីស្វែងយល់អំពី ការធ្វើសម្ភាសន៍ ការសម្តែងសាកល្បង និង/ឬ ថ្ងៃខែ និងម៉ោង ដើរមើលសាលា។

**បើមានសំណួរ?**

សូមទាក់ទងទៅ ការិយាល័យផ្នែក ចុះឈ្មោះ និងចាត់តាំង សិស្ស **តាម**

អ៊ីមែល schoolselect@philasd.org ឬ ទូរស័ព្ទលេខ ២១៥-៤០០-៤២៩០។